មន្ទីរពេទ្យ
កាល់ម៉ែត
HOPITAL
Calmette

ករុណា ការប្តេជ្ញា ឧត្តមភាព ប្រសិទ្ធភាព ទំនើបកម្ម

# ព្រឹត្តិបត្រសុខភាព មន្ទីរពេទ្យ កាល់ម៉ែត

## Calmette's Newsletter Nº 07

ខែ កក្កដា ២០១៨ - កញ្ញា ២០១៨

ព្រឹត្តិបត្រលេខ ៧



រៀបចំដោយ
គណៈកម្មការទស្សនាវដ្តីនៃមន្ទីរពេទ្យកាល់ម៉ែត

# ទំព័រផ្សេងៗ

ខែ កក្កដា ២០១៨ - កញ្ញា ២០១៨

ទស្សនាវដ្តីលេខ ៧

**1** សិក្ខាសាលាពិភាក្សារួមគ្នារវាង ជប៉ុន និង កម្ពុជានៅមន្ទីរពេទ្យកាល់ម៉ែត នៃព្រះរាជាណាចក្រកម្ពុជា!

**2** វគ្គបណ្តុះបណ្តាលស្តីពី "ការត្រួតពិនិត្យ និងបង្ការការចម្លងរោគក្នុងមន្ទីរពេទ្យ (Infection Prevention control)"





**3** ម្តាយក្តៅខ្លួនក្នុងអំឡុងពេលមានផ្ទៃពោះ អាចប៉ះពាល់ដល់ទារកឬទេ?

**4** អត្ថប្រយោជន៍ នៃការថតវាស់កំហាប់ឆ្អឹង (Bone Densitometry)!

**5** តើអ្នកធ្លាប់បានដឹងអំពីជំងឺដុំសរសៃប្រសាទបញ្ជាស្ថិតនៅនឹងឆ្អឹងកងខ្នងដែរ ឬទេ?

**6** ជំងឺចប់បារម្ភគឺជាជំងឺដែលអាចព្យាបាលបាន!





**7** តើស្ត្រីមានផ្ទៃពោះជាមធ្យមក្នុងរយៈពេលប៉ុន្មានក្រោយរៀបការ? និង តើគូរស្វាមីភរិយាជាទូទៅ ត្រូវរង់ចាំរយៈពេលប៉ុន្មានក្នុងការចង់មានផ្ទៃពោះ?

**8** ស្ថានភាព ផល្លី ៣ខែ ក្រោយបាក់ឆ្អឹងក!

**9** សំណួរចម្លើយ Quiz? ទាក់ទងនឹងសុខភាព









www.facebook.com/calmette.gov.kh

hospital@calmette.gov.kh

www.calmette.gov.kh





# សិក្ខាសាលាពិភាក្សារួមគ្នារវាង ជប៉ុន និង កម្ពុជានៅមន្ទីរពេទ្យកាល់ម៉ែត នៃព្រះរាជាណាចក្រកម្ពុជា!





ផ្តើមចេញអំពីទស្សនកិច្ចកម្រិតថ្នាក់ដឹកនាំមន្ទីរពេទ្យនាឆ្នាំ ២០១៦ នៅប្រទេសជប៉ុន អំពីវិស័យអភិវឌ្ឍមន្ទីរពេទ្យ និងជាពិសេសកិច្ចការរៀបចំ និងដំណើរការផ្នែកសង្គ្រោះបន្ទាន់បឋមមុនមកដល់មន្ទីរពេទ្យនិងក្នុងមន្ទីរពេទ្យ ក៏ដូចជាជំនាញថែទាំផ្សេងៗក្នុងមន្ទីរពេទ្យ សិក្ខាសាលា ពិភាក្សារួមគ្នាមួយថ្មីទៀតត្រូវបានរៀបចំឡើងនាថ្ងៃសុក្រ ៣រោច ខែជេស្ឋ ឆ្នាំចសំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី ០១ ខែមិថុនា ឆ្នាំ២០១៨ នៅ មន្ទីរពេទ្យកាល់ម៉ែត នៃ ព្រះរាជាណាចក្រកម្ពុជា ដោយមាន ការចូលរួមធ្វើបទ បង្ហាញអំពីអ្នកជំនាញការផ្នែកមន្ទីរពេទ្យ មកពីប្រទេសជប៉ុន ក្នុងគោលបំណងចែករំលែកបទពិសោធន៍ចំណេះដឹងថ្មីៗ ក្នុងជំនាញបច្ចេកទេសសង្គ្រោះបន្ទាន់ និង បទពិសោធន៍ អំពីការគ្រប់គ្រងស្ថានភាពជំងឺមុនមកដល់ មន្ទីរពេទ្យនិងក្នុងមន្ទីរពេទ្យ ព្រមទាំងចំណេះដឹងបទពិសោធន៍អំពីការរៀបចំបញ្ជូនអ្នកជំងឺ ពីកន្លែងមួយទៅកន្លែងមួយ ក្នុងស្ថានភាពសមស្រប និងដោយសុវត្ថិភាពខ្ពស់បំផុត។





បន្ថែមពីជំនាញខាងលើ បទពិសោធន៍ និងចំណេះដឹងផ្សេងៗលើជំនាញ និងបច្ចេកទេសផ្នែកផ្សាំសរីរាង្គ ជំនាញថែទាំអ្នកជំងឺវ័យជរា ក៏ជាប្រធានបទសំខាន់ដែលបានលើកមកបង្ហាញ និងពិភាក្សាផងដែរ។

កិច្ចសហប្រតិបត្តិការបច្ចេកទេសវេជ្ជសាស្ត្រនៃប្រទេសទាំងពីរ ក៏ផ្តោតជាអាទិភាពសំខាន់លើវិស័យ បណ្តុះបណ្តាលធនធានមនុស្សកម្រិតអ្នកជំនាញកម្រិតខ្ពស់ដែលតម្រូវឱ្យមានការផ្លាស់ប្តូរគ្នាទៅវិញទៅមក តាមទស្សនៈកិច្ចសិក្សានៅប្រទេសជប៉ុន និងកម្ពុជា។











# វគ្គបណ្តុះបណ្តាលស្តីពី
# “ការត្រួតពិនិត្យ និងបង្ការការចម្លងរោគក្នុងមន្ទីរពេទ្យ (Infection Prevention control)”

នាថ្ងៃព្រហស្បតិ៍ ១រោច ខែ បឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ២០១៨ មន្ទីរពេទ្យកាល់ម៉ែត បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី "ការត្រួតពិនិត្យ និងបង្ការការចម្លងរោគក្នុងមន្ទីរពេទ្យ" ដែលប្រព្រឹត្តទៅមានរយៈពេល ២ថ្ងៃ។ គោលបំណងនៃវគ្គបណ្តុះបណ្តាលនេះ គឺបង្កើនចំណេះលើការបង្ការការចម្លង រោគនៅក្នុងមន្ទីរពទ្យ ដល់បុគ្គលិក ជាគិលានុបដ្ឋាក-យិកា ឆ្មប ដែលទើបចូលបម្រើការងារ ថែទាំ លើចំណុចសំខាន់ៗមាន៖

១- អនាម័យដៃ

២- ការបង្ករោគ ប្រភពនៃមេរោគ និងការត្រួតពិនិត្យ ការបង្ការការចម្លងរោគ

៣- ការសម្លាប់មេរោគ ស្តេរីលសម្ភារៈ

៤- ការបង្ការ និងថែទាំ ពេលមុត ឬខ្ទាតប្រឡាក់ឈាម





# ម្ដាយក្ដៅខ្លួនក្នុងអំឡុងពេលមានផ្ទៃពោះ **អាចប៉ះពាល់ដល់ទារក ឬទេ?**




ក្ដៅខ្លួនក្នុងអំឡុងពេលមានផ្ទៃពោះ គឺជាការកើនឡើងកម្ដៅខ្លួន លើស ឬស្មើ ៣៧.៨ អង្សារសេ។

**១) មូលហេតុៈ**

កត្តាដែលនាំឱ្យមានការកើនឡើងកំដៅក្នុងអំឡុងពេលមានផ្ទៃពោះ មានបីប្រភេទគឺ:

**ក. មូលហេតុមិនសូវធ្ងន់ធ្ងរៈ**

- រលាកត្រចៀក
- រលាកបំពង់ក
- រលាកទងសួត
- ផ្ដាសាយធំ

**ខ. មូលហេតុធ្ងន់ធ្ងរៈ**

- ការរលាកតម្រងនោម
- ការរលាក ប្រដាប់បន្តពូជ
- ការរលាកស្រោមទឹកភ្លោះ
- ស្លួច, Toxoplasmose, cytomegalovirus, herpès, រលាកសួត ,ស្រឡទែន រលាកថ្លើមប្រភេទ B ,C, របេង, listeriose , ជំងឺអេដស៍។

**គ. មូលហេតុធ្ងន់ធ្ងរដែលតម្រូវឱ្យមានការវះកាត់បន្ទាន់មានដូចជា:**

- រលាកខ្នែងពោះវៀន
- រលាកថង់ទឹកប្រមាត់

**២) រោគសញ្ញាៈ**

អាការៈដែលអាចកើតមានឡើងគួបផ្សំជាមួយការកើនឡើងនៃកំដៅមានៈ

**ក. សញ្ញានៃការពិបាកបត់ជើងតូចមានដូចជា:**

- ពិបាកនោម
- នោមមិនអស់
- នោមក្រហាយ
- ឈឺចង្កេះ
- នោមមានឈាម

**ខ. សញ្ញាផ្នែកប្រដាប់រំលាយអាហារៈ**

- រាករូស
- ក្អួត ចង្អោរ
- ចុកពោះ

**គ. សញ្ញាផ្លូវដង្ហើមៈ**

- ក្អក
- ហត់
- ពិបាកដកដង្ហើម
- ចប់ដើមទ្រូង

**ឃ. សញ្ញានៃប្រដាប់បន្តពូជៈ**

- ធ្លាក់សខ្លាំង មានក្លិនស្អុយ
- ការធ្លាក់ឈាម
- ការហូរខ្ទុះ

*បញ្ជាក់: ចំពោះការបង្ករោគដោយប៉ារ៉ាស៊ីត វីរុស ឬបាក់តេរីមួយចំនួនធំ គឺមិនបណ្ដាលឱ្យមានសញ្ញាគំអួញអ្វីទាំងអស់ ដូច្នេះទាមទារឱ្យស្ត្រីមានផ្ទៃពោះទាំងអស់ត្រូវមកពិនិត្យផ្ទៃពោះ និងធ្វើតេស្តឈាមរកមេរោគមួយចំនួន ឲ្យបានទៀងទាត់ និងទាន់ពេលវេលា។

**៣) កត្តាប្រឈម**

ហានិភ័យដែលអាចកើតមានឡើង បណ្ដាលមកពីគ្រុនក្ដៅក្នុងអំឡុងពេលមានផ្ទៃពោះមានដូចជា:

- អាចបណ្ដាលឱ្យរលូតកូន
- កូនកើតមិនគ្រប់ខែ
- ទារកស្លាប់ក្នុងពោះ
- ជំងឺដែលអាចកើតមានលើទារកដែលបណ្ដាលមកពីការឆ្លងរោគពីម្ដាយ ទៅ កូន។

**៤) វិធីការពារ និងព្យាបាលៈ**

- ត្រូវនៅឱ្យឆ្ងាយពីសត្វឆ្មា ឬសត្វអាចបង្ករោគមួយចំនួនទៀត
- មិនត្រូវបរិភោគ សាច់ឆៅ ឬបន្លែឆៅ ដែលលាងសម្អាតមិនបានស្អាតល្អ
- មិនត្រូវបរិភោគ អាហារផ្អាប់ ឬអាហាររក្សាក្នុងទូរទឹកកកករយៈពេលយូរ ព្រោះវាមានផ្ទុកនូវប៉ារ៉ាស៊ីតមួយចំនួន
- ត្រូវនៅឱ្យឆ្ងាយពីក្មេង ឬកុមារដែលកើតអុតស្វាយ ឬស្អូចព្រោះ បណ្ដាលឱ្យឆ្លងបាន
- ត្រូវមកពិនិត្យផ្ទៃពោះ និងពិនិត្យឈាមដើម្បីស្វែងរកមេរោគមួយចំនួន ដែលអាចបង្កហានិភ័យដល់ទារកក្នុងផ្ទៃ

**មិនត្រូវបរិភោគសាច់ឆៅ ដែលលាងសម្អាតមិនបានស្អាតល្អ**



**មិនត្រូវបរិភោគបន្លែឆៅ ដែលលាងសម្អាតមិនបានស្អាតល្អ**



ប្រសិនបើមានអាការៈក្ដៅខ្លួន កំដៅលើស ឬស្មើ ៣៧.៨ អង្សាសេ ត្រូវមកជួបពិគ្រោះជាមួយវេជ្ជបណ្ឌិតជំនាញនៃមន្ទីរពេទ្យកាល់ម៉ែតជាបន្ទាន់ ដើម្បីស្វែងរកមូលហេតុ និងទទួលបានការព្យាបាលឱ្យបានទាន់ពេលវេលា ជៀសវាងការបង្កគ្រោះថ្នាក់ដល់ម្ដាយ និងទារកក្នុងផ្ទៃ។

“សុភមង្គលក្នុងគ្រួសារបានដោយសារ គ្មានការចម្លងមេរោគចំពោះម្ដាយ និងកូន”

# អត្ថប្រយោជន៍ នៃការថតវាស់កំហាប់ឆ្អឹង (Bone Densitometry)!

១) អាចវិភាគដឹងពី កំហាប់ឆ្អឹងជា ៣កម្រិត៖ ឆ្អឹងធម្មតា ឆ្អឹងខ្សោយ(Osteopenia) និងឆ្អឹងពុក (Osteoporosis) ។

២) ជំងឺឆ្អឹងខ្សោយ និងឆ្អឹងពុក ជាជំងឺដែលអាចការពារ និងព្យាបាលបាន ជាពិសេសបើរកឃើញនៅដំណាក់កាលដំបូងៗ ។

៣) អាចឱ្យយើង វាយតម្លៃហានិភ័យ នៃការបាក់ឆ្អឹង (Fracture risk) ដែលអនុញ្ញាតឱ្យគ្រូពេទ្យធ្វើការព្យាបាលនិងបង្ការជាមុន។

៤) ថតដើម្បីតាមដានវាយតំលៃប្រសិទ្ធភាពនៃការព្យាបាល ប្រកបដោយសុក្រឹតភាពខ្ពស់។

៥) ជាការថតសាមញ្ញ ប្រសិទ្ធភាពខ្ពស់ រហ័ស និង មានសុវត្ថិភាពបំផុត។

សូមអញ្ជើញមកថតពិនិត្យសុខភាពឆ្អឹងរបស់លោកអ្នកនៅមន្ទីរពេទ្យកាល់ម៉េត។













ការថតវិភាគកំហាប់លើឆ្អឹងកំភួនដៃ




ការថតវិភាគកំហាប់លើឆ្អឹងត្រគាក




ការថតវិភាគកំហាប់លើឆ្អឹងកងខ្នង



# តើអ្នកធ្លាប់បានដឹងអំពីជំងឺដុំសរសៃប្រសាទបញ្ញាស្ថិតនៅនឹងឆ្អឹងកងខ្នងដែរ ឬទេ?

ជាដុំដែលកើតចេញពីស្រោមនៃសរសៃបញ្ញា (Neurinome Rachidien) ដែលជាទូទៅវាជាដុំសាច់ស្លូត និងរីកលូតលាស់យឺត។

**ក) រោគសញ្ញា៖**

- ឈឺចាប់ដៃ ជើង
- ស្ពឹកដៃ ជើង
- ទន់ដៃ ជើង
- មិនអាចបញ្ជាលើការបន្ទោរបង់បាន
- លក្ខណៈពិសេសមួយទៀតនោះ គឺការឈឺចាប់កាន់តែខ្លាំងនៅពេលយប់




**ខ) ការធ្វើរោគវិនិច្ឆ័យ៖**

ដើម្បីដឹងច្បាស់ពីរោគវិនិច្ឆ័យករណីនេះ
ត្រូវពិនិត្យដោយផ្ទាល់ទៅលើអ្នកជំងឺតាមរយៈគ្រូពេទ្យជំនាញ
អមដោយការថតស្កាន់ន័រ និងការថតដោយអឹម វ៉ាយ (IRM)។




**គ) ការវិវត្តន៍៖**

ការរីកធំឡើងបន្តិចម្តងៗរបស់ដុំសាច់ ដោយស្តែងឡើងដោយការឈឺចុកចាប់ ស្ពឹក និងអាចឈានទៅរកពិការភាពអស់មួយជីវិត។




**ឃ) ការព្យាបាល៖**

មានតែវិធីវះកាត់យកចេញទេ ដែលជាជំរើសដ៏ល្អបំផុតសម្រាប់ការព្យាបាលជំងឺដុំសរសៃប្រសាទបញ្ញា។



« ប្រសិនបើលោកអ្នកមានបញ្ហាដែលទាក់ទងទៅនឹងការកៀបខួរឆ្អឹងខ្នង និងសរសៃ ប្រសាទបញ្ញា សូមមេត្តាប្រញាប់មកពិគ្រោះជាមួយក្រុមសាស្ត្រាចារ្យវេជ្ជបណ្ឌិតឯកទេស នៃមន្ទីពេទ្យកាល់ម៉ែត ដើម្បីទទួលបាននូវរោគវិនិច្ឆ័យ និងវិធីសាស្រ្តព្យាបាល ទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាពខ្ពស់។»

**ផ្ទៀងផ្ទាត់ចម្លើយ — សំណួរចម្លើយ Quiz ទាក់ទងនឹងសុខភាព ទំព័រ ០៧**

Q1: ១ Q3: ២

Q2: ១ Q4: ៣ & ៤




# ជំងឺថប់បារម្ភគឺជាជំងឺដែលអាចព្យាបាលបាន!

**១) អ្វីជាជំងឺថប់បារម្ភ ?**

ពាក្យថា "ថប់បារម្ភ" មានន័យថាមានអារម្មណ៍ធុញថប់ ព្រួយបារម្ភ ឬភ័យខ្លាច។ អាការៈថប់បារម្ភអាចស្តែងចេញដូចជាឧស្សាហ៍ញ័រទ្រូង ញ័រដៃ អួលដើមក បែកញើស ទន់ដៃទន់ជើង អស់កម្លាំង តឹងក្បាល តឹងកញ្ចឹងក ចុករោយសាច់ដុំ ស្ងួតមាត់ ចេះតែចង់បត់ជើង មានអារម្មណ៍មិនស្រួលក្នុងខ្លួន ខ្លាចថាគាំងបេះដូង ខ្លាចទៅជាឆ្កួត ជាដើម។ ជំងឺថប់បារម្ភជាចង្កោមនៃជំងឺជាច្រើនដូចជា ជំងឺស្រីត ជំងឺអាកូរ៉ាហ្វូបៀ ជំងឺថប់បារម្ភសង្គម និងជំងឺថប់បារម្ភទូទៅជាដើម។



**២) ការវិវត្ត និង ផលវិបាក៖**

ជំងឺថប់បារម្ភច្រើនមានលក្ខណៈរ៉ាំរ៉ៃ បើមិនព្យាបាល គឺវាអាចនៅបន្តដល់រាប់ឆ្នាំ ឬ សឹងមួយជីវិតក៏មាន ដែលរំខានជាខ្លាំងដល់កិច្ចការប្រចាំថ្ងៃ ហើយក្នុងករណីខ្លះ អ្នកជំងឺអាចទៅជាឧស្សាហ៍ធ្វើទុក្ខក្នុងខ្លួន ទៅជាអស់សង្ឃឹមលែងចង់រស់ ឬទៅប្រើប្រាស់ថ្នាំងងុយគេង ស្រា និងគ្រឿងញៀន ដែលនាំឲ្យកាន់តែប៉ះពាល់ដល់សុខភាពថែមទៀត។

**៣) ការព្យាបាល៖**

យ៉ាងណាក៏ដោយ
ជំងឺថប់បារម្ភអាចព្យាបាលជាសះស្បើយដោយប្រើប្រាស់ឱសថ
និងការព្យាបាលចិត្តសាស្ត្រពីសំណាក់គ្រូពេទ្យឯកទេស។



សូមចងចាំថា ការមានជំងឺថប់បារម្ភ មិនមែនបានន័យថាអ្នកទន់ខ្សោយ មិនចេះគ្រប់គ្រងចិត្តខ្លួនឯង ឬចរិតមានបញ្ហានោះទេ ។ វាជាជំងឺដែលគេឧស្សាហ៍ជួបប្រទះ ដូចគ្នានឹងជំងឺលើសឈាម ទឹកនោមផ្អែម ឬរលាកសន្លាក់ដែរ។ អ្វីដែលល្អ គឺមានការព្យាបាលប្រកបដោយប្រសិទ្ធភាពសម្រាប់ជំងឺថប់បារម្ភ ។

«ប្រសិនបើលោក លោកស្រី សង្ស័យថា លោក លោកស្រី ឬមនុស្សដែលលោក លោកស្រីស្គាល់ មានជំងឺថប់បារម្ភ សូមអញ្ជើញមកទទួលការពិគ្រោះ និងព្យាបាលដោយក្រុមវេជ្ជបណ្ឌិតឯកទេសនៅមន្ទីរពេទ្យកាល់ម៉ែត។»



«ប្រសិនបើលោក លោកស្រី សង្ស័យថា លោក លោកស្រី ឬមនុស្សដែលលោក លោកស្រីស្គាល់ មានជំងឺថប់បារម្ភ សូមអញ្ជើញមកទទួលការពិគ្រោះ និងព្យាបាលដោយក្រុមវេជ្ជបណ្ឌិតឯកទេសនៅមន្ទីរពេទ្យកាល់ម៉ែត។»

# តើស្ត្រីមានផ្ទៃពោះជាមធ្យមក្នុងរយៈពេលប៉ុន្មានក្រោយរៀបការ? និង តើគូស្វាមីភរិយាជាទូទៅ ត្រូវរង់ចាំរយៈពេលប៉ុន្មានក្នុងការចង់មានផ្ទៃពោះ?




ស្ត្រីម្នាក់ៗតែងតែមានលក្ខណៈដូចៗគ្នា កត្តាជាច្រើនអាចបណ្តាលឱយមានបម្រែបម្រួលអរមូន និងសរីរាង្គរបស់ ស្ត្រី ដូចជាកត្តាផ្លូវកាយនិងផ្លូវចិត្តជាកត្តាបង្កើនរយៈពេលនៃការមានផ្ទៃពោះ។ ជាទូទៅគូស្វាមីភរិយាត្រូវរងចាំ នឹងចំណាយពេលជាមធ្យម៧ខែក្នុងមួយឆ្នាំ ដើម្បីទទួលបានលទ្ធផលវិជ្ជមាន" ពេលវេលាដែលត្រូវការដើម្បីមានគភ៌"។

ពេលវេលានេះប្រែប្រួលពីស្ត្រីម្នាក់ទៅស្ត្រីម្នាក់ទៀត យោងតាមសក្តានុពលនៃការមានកូនរបស់គាត់។ រយៈពេលជាមធ្យមដើម្បីមានផ្ទៃពោះគឺរវាង៣និង៦ ខែសម្រាប់គូស្នេហ៍វ័យក្មេង ហើយបង្កើនទៅតាមអាយុ។ និយាយរួមរយៈពេលជាមធ្យមដើម្បីមានផ្ទៃពោះ គឺអាស្រ័យលើកត្តារាងកាយ។

**ក**) ការពន្យារកំណើតនិងការមានផ្ទៃពោះ ៖

រឿងដំបូងដែលស្ត្រីម្នាក់គិតចង់បង្កើតកូន គឺជាការបញ្ឈប់រាល់វិធានការពន្យារកំណើត។ នៅពេលដែលប្រើថ្នាំផ្លាស់ប្តូរវដ្តរដូវធម្មជាតិ ស្ត្រីម្នាក់នោះនឹងត្រូវការពេលវេលា ដើម្បីទទួលបានវដ្តធម្មតាវិញ ហើយកុំបារម្ភប្រសិនបើអ្នកមិនមានផ្ទៃពោះជាលើកដំបូង។

**ខ**) អាយុមានឥទ្ធិពលលើពេលវេលាជាមធ្យមដែលវាត្រូវការ ពេលមានផ្ទៃពោះ នៅពេលអាយុកាលរបស់ស្ត្រីកើនឡើង ស្ត្រីមិនសូវមានកូនទេ ពោលគឺរយៈពេលមធ្យមក្នុងការមានផ្ទៃពោះ។







**គ**) រយៈពេលជាមធ្យមដើម្បីមានផ្ទៃពោះរហូតដល់ទៅ ៣០ឆ្នាំមុនពេលអាយុ ៣០ឆ្នាំលទ្ធភាពនៃការមានផ្ទៃពោះគឺ២៥%ក្នុងមួយវដ្តជាមធ្យម ហើយ ៨៥% នៃគូស្វាមីភរិយា មានផ្ទៃពោះក្នុងឆ្នាំដំបូង និង៩០% បន្ទាប់ពី ពីរឆ្នាំ។ រយៈពេលជាមធ្យមដើម្បីមានផ្ទៃពោះក្នុងរវាង ៣ និង ៦ ខែសម្រាប់ គូស្នេហ៍វ័យក្មេង។ ស្ត្រីអាយុ ៣០ឆ្នាំមានអត្រាជាមធ្យម ៧៥% ដែលមាន កូនក្នុងអំឡុងពេល ១២ ខែក្រោយការបញ្ឈប់ការពន្យារកំណើតរបស់នាង។

**ឃ**) ស្ត្រីបន្ទាប់ពី ៣០ឆ្នាំ៖ស្ត្រីចាប់ពីអាយុ៤០ឆ្នាំ ឱកាសនៃការមានផ្ទៃពោះក្នុងមួយវដ្តធ្លាក់ចុះដល់៦%។ ការធ្លាក់ចុះនៃលទ្ធភាពនៃការមានផ្ទៃពោះអាចកើនឡើងបន្ទាប់ពីអាយុ៣៦ឆ្នាំ ហើយស្ត្រីអាយុ៤០ឆ្នាំ មានឱកាសជាមធ្យម៤៤% ក្នុងការមានកូន ក្នុងកំឡុង ពេល ១២ខែនៃការបញ្ឈប់ការពន្យារកំណើតរបស់នាង។




គូស្វាមីភរិយាទាំងអស់តែងតែប្រាថ្នាចង់បានកូនជាកាដូរអាពាហ៍ពិពាហ៍ ដើម្បីបង្កើនប្រសិទ្ធភាពពេលវេលាជាមធ្យម ដើម្បីមានផ្ទៃពោះដំបូង ស្ត្រីត្រូវ មានសុខភាពល្អទាំងផ្លូវកាយ និងផ្លូវចិត្ត។ ស្ត្រីត្រូវថែរក្សាសុខភាពខ្លួនឯង ឱ្យល្អ ហើយត្រូវចាំថាកូននោះជាកាដូរនៃសេចក្តីស្រឡាញ់របស់នាក់។



ជម្រា ប ថា ម ន្ទី រ ពេ ទ្យកាល់ម៉ែតមានសេវា ពិនិត្យ និងពិគ្រោះលើវិបត្តិអត់កូនជាមួយនិងក្រុមគ្រូពេទ្យជំនាញឯកទេសសម្ភព និងរោគស្ត្រី។




# ស្ថានភាព ផល្លី ៣ខែ ក្រោយបាក់ឆ្អឹងក!









ប្អូនស្រីផល្លី អាយុ២៥ឆ្នាំ ជាស្ត្រីមេម៉ាយដែលមានកូនប្រុសអាយុ៤ឆ្នាំ កើតក្នុងគ្រួសារកសិករ នៅខេត្តស្វាយរៀង បានទទួលគ្រោះថ្នាក់ក្រឡាប់រថយន្តពេលកំពុងធ្វើដំណើរទៅធ្វើការរោងចក្រនៅក្រុងបាវិត ក្នុងអំឡុង ខែតុលា ឆ្នាំ២០១៦។

ក្រោយពីគ្រោះថ្នាក់ភ្លាមៗ ផល្លីមានអារម្មណ៍ ឈឺកញ្ចឹងកខ្លាំង ស្ពឹកដៃ ស្ពឹកជើង កម្រើកស្ទើរតែមិនរួច។ ប្អូនស្រីត្រូវបានរថយន្តសង្គ្រោះបន្ទាន់ដឹកមកមន្ទីរពេទ្យខេត្តស្វាយរៀង និងបានបញ្ជូនបន្តមកមន្ទីរពេទ្យកាល់ម៉ែតនៅថ្ងៃដដែល។ មកដល់មន្ទីរពេទ្យផ្នែកសង្គ្រោះបន្ទាន់ ដោយមានរណបកនៅជាប់នឹងក ផល្លីនៅមានស្មារតីធម្មតា។ ក្រោយពីការពិនិត្យយ៉ាងយកចិត្តទុកដាក់ពីសំណាក់ក្រុមគ្រូពេទ្យមន្ទីរពេទ្យកាល់ម៉ែត ឃើញថាការកម្រើកទាំងដៃ និងជើងរបស់ផល្លីមានកម្រិតខ្សោយ។ ការធ្វើរោគវិនិច្ឆ័យដោយការថតស្កេនឆ្អឹងកងក ឃើញថាគាត់ភ្លាត់ឆ្អឹងកងកទី៤ និងទី៥។ ការវះកាត់តឆ្អឹងក ដើម្បីសង្គ្រោះជីវិតត្រូវបានធ្វើជាបន្ទាន់ក្រោយការធ្វើរោគវិនិច្ឆ័យរួចរាល់។ ក្រោយការវះកាត់ សភាពរបស់ប្អូនស្រីវិវត្តទៅរកភាពប្រក្រតីយ៉ាងឆាប់រហ័ស ពោលគឺគាត់អាចដើរទៅផ្ទះវិញដោយខ្លួនឯង បន្ទាប់ពីវះកាត់បាន១៥ថ្ងៃ។ រយៈពេល៣ខែក្រោយការវះកាត់ ផល្លីអាចទៅធ្វើការរកប្រាក់ដើម្បីចិញ្ចឹមជីវិត និងកូនប្រុសជាទីស្រឡាញ់របស់គាត់វិញជាធម្មតា។

ប្អូនស្រី ផល្លី មានទឹកចិត្តរំភើបក្រៃលែង និងសូមអរគុណ វេជ្ជបណ្ឌិតជំនាញក៏ដូចជាមន្ទីរពេទ្យកាល់ម៉ែត ដែលមានបច្ចេកទេសជំនាញ និងសម្ភារៈទំនើបគ្រប់គ្រាន់ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ក្នុងការជួយសង្គ្រោះជីវិតផល្លី ឲ្យវិលមករកសភាពធម្មតា និងអាចប្រកបជីវភាពប្រក្រតីវិញបានយ៉ាងឆាប់រហ័ស។

# សំណួរចម្លើយ Quiz?

## ទាក់ទងនឹងសុខភាព



Q1. តើមួយណាដែលមិនមែនជារោគសញ្ញាជំងឺពុកឆ្អឹង

១. បាក់ឆ្អឹងក្រោយពីរងគ្រោះថ្នាក់ស្រាល
២. ឈឺឆ្អឹងកងចង្កេះ
៣. ឈឺក្បាល



Q2. តើការលើកឡើងខាងក្រោមនេះពិត ឬមិនពិត? អ្នកជំងឺទឹកនោមផ្អែមប្រភេទទីពីរប្រឈមមុខខ្ពស់នឹងជំងឺសរសៃឈាមបេះដូងជាងមនុស្សទូទៅ!

១. ពិត
២. មិនពិត



Q3. ជាទូទៅស្ត្រីដែលមានផ្ទៃពោះគ្រប់ខែ គឺត្រូវធ្វើការសម្រាលបុត្រនៅគភ៌ ដែលមានអាយុចន្លោះពី៖

១. ៣៥ ទៅ ៣៧សប្តាហ៍
២. ៣៧ ទៅ ៤0សប្តាហ៍
៣. ៤១សប្តាហ៍ឡើងទៅ



Q4. តើជំងឺដំបៅក្រពះ គ្រូពេទ្យអាចធ្វើរោគវិនិច្ឆ័យបានយ៉ាងដូចម្តេច?

១. មើលឈាម
២. មើលអេកូ
៣. ផ្លុំខ្យល់រកមេរោគក្រពះ
៤. ឆ្លុះក្រពះ



សូមមេត្តាផ្ទៀងផ្ទាត់ចម្លើយនៅទំព័រ ៥



ឧបត្ថម្ភដោយ

Expertise for the Promotion of Health

លេខ ៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
ទូរស័ព្ទលេខ: ០១១ ៤១ ៤០ ៦៥, ០៧៧ ៣៦ ១៧ ៥១, ០១៧ ៨៦ ៦៨ ៤៧
អ៊ីម៉ែល: hospital@calmette.gov.kh, វេបសាយ: www.calmette.gov.kh
ហ្វេសប៊ុក: www.facebook.com/calmette.gov.kh


ព្រឹត្តិបត្រសុខភាពមន្ទីរពេទ្យកាល់ម៉ែត
ព្រឹត្តិបត្រសុខភាពមន្ទីរពេទ្យកាល់ម៉ែត